# សម្ភាសន៍ជាមួយ មៀច ជ្រួន ភេទប្រុស អាយុ៦១ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម“កងចល័តភូមិភាគ”

## ស្រុកកំណើតនៅភូមិសន្តិភាព ឃុំទ្រា ស្រុកសំរោង ខេត្តតាកែវ

## រស់នៅភូមិច្រកជាំស្រងាំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ចាន់ ប្រុញ

## ០០:៤៩:០៦

## ១៩ទំព័រ

ប្រុញៈ ខ្ញុំអត់មានអីកត់ អីចឹងខ្ញុំសុំថតសំលេងគ្រាន់តែកត់ត្រាទុកជាប្រវត្តិ ។ អត់ទោសអ៊ំឈ្មោះអីដែរ?

ជ្រួនៈ មៀច ជ្រួន ។

ប្រុញៈ មៀច ជ្រើន?

ជ្រួនៈ មៀន ជ្រួន ។

ប្រុញៈ មៀច ជ្រួន?

ជ្រួនៈ បាទ!

ប្រុញៈ ហើយអ៊ំអាយុប៉ុន្មានហើយរាល់ថ្ងៃ?

ជ្រួនៈ អាយុ៦១ហើយ ។

ប្រុញៈ អ៊ំនៅស្រុកកំណើតណាវិញ?

ជ្រួនៈ ស្រុកកំណើតនៅភូមិសន្តិភាព ឃុំទ្រា ស្រុកសំរោង ខេត្តតាកែវ ។

ប្រុញៈ អ៊ំរៀនដល់ថ្នាក់ណាដែរ?

ជ្រួនៈ ខ្ញុំថ្នាក់ទី៨ ។

ប្រុញៈ ទី៨សម័យមុន?

ជ្រួនៈ បាទ!

ប្រុញៈ អ៊ំឈប់រៀនឆ្នាំណា?

ជ្រួនៈ ឈប់រៀនឆ្នាំ៦៣-៦៤ ។

ប្រុញៈ ម៉េចបានអ៊ំឈប់រៀនអីចឹង?

ជ្រួនៈ ឈប់ព្រោះខ្ញុំរស់នៅជាមួយម្ដាយ ឪពុកខ្ញុំមានម្ដាយចុង ។

ប្រុញៈ ឪពុកអ៊ំឈ្មោះអីគេ?

ជ្រួន៖ ឈ្មោះ មៀច សេង ។

ប្រុញ៖ ហើយម្តាយអ៊ំឈ្មោះអីគេ?

ជ្រួន៖ ម្តាយខ្ញុំនួយ តែ គាត់ស្លាប់តាំងពីខ្ញុំអត់ទាន់ដឹងគាត់ស្លាប់ ខ្ញុំនៅតូច គាត់យកប្រពន្ធក្រោយទៀត ។

ប្រុញ៖ អត់ទោសម៉ិញអ៊ំឈ្មោះអីគេ?

ជ្រួន៖ មៀច ជ្រួន ។

ប្រុញ៖ ចុះប្រពន្ធអ៊ំឈ្មោះអីគេ?

ជ្រួន៖ ទឹម សួង ។

ប្រុញ៖ អ៊ំរាល់ថ្ងៃមកដល់នៅក្នុងភូមិនេះ ភូមិអីគេ?

ជ្រួន៖ នេះភូមិប្រកជាំស្រង៉ាំ ។

ប្រុញ៖ ប្រកជាំស្រង៉ាំ ឃុំ?

ជ្រួន៖ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ប្រុញ៖ ឃុំមកនៅនេះប៉ុន្មានឆ្នាំហើយ?

ជ្រួន៖ ខ្ញុំនៅ១១ឆ្នាំ ។

ប្រុញ៖ អ៊ំចូលរួមជាមួយចលនាខ្មែរក្រហមតាំងពីឆ្នាំណាមក?

ជ្រួន៖ ខ្ញុំចូលតាំងពីនៅស្រុក ខ្ញុំចូល៧៣ ។

ប្រុញ៖ ម៉េចបានអ៊ំចូលអីចឹង?

ជ្រួន៖ ចូលកាលហ្នឹងកងរំដោះ ចូល៧៣ហ្នឹងចូលនៅវ៉ៃកំពង់ស្ពឺ ។

ប្រុញ៖ ខាងកងរំដោះចូលមកវ៉ៃកំពង់ស្ពឺ?

ជ្រួន៖ វ៉ៃជាមួយលន់ នល់ ។

ប្រុញ៖ អីចឹងអ៊ំពេលហ្នឹងចូលធ្វើអី?

ជ្រួន៖ ធ្វើកងទ័ព ។

ប្រុញ៖ នៅពេលកងទ័ពហ្នឹងពីណាគ្រប់គ្រង?

ជ្រួន៖ កងទ័ពកាលពីហ្នឹង កាលមុនថាសម្តេច ដល់ពេលរៀនឯកសារយើងធ្វើកងទ័ពរៀនឯកសារក្នុងព្រៃ គេថាបំបាត់លោក បំបាត់ស្តេច កូនកសិករក៏ធ្វើបានដែរ អ្នកធ្វើទ័ពបានដឹង ។

ប្រុញ៖ ឯកសារហ្នឹងបានពីណាអ៊ំ?

ជ្រួន៖ ឯកសារមេៗគេប្រជុំ គេប្រជុំយើងរាល់ថ្ងៃកងទ័ពនៅក្នុងព្រៃ អ្នកសង្គ្រាមទៅហើយអ្នកសំរាកក្រោយរៀននៅក្នុងព្រៃ ។

ប្រុញៈ ឯកសារហ្នឹងគេថាម៉េចអ៊ំ?

ជ្រុនៈ គេប្រជុំយើង គេរៀនថា ទៅមុខគេបំបាត់លោក និងបំបាត់ស្ដេច កូនកសិករក៏ធ្វើស្ដេចបានដែរ ។

ប្រុញៈ ហេតុអីបានគេចង់បំបាត់លោកអ៊ីចឹង?

ជ្រុនៈ មិនដឹង កាលហ្នឹងជំនាន់នៅហ៊ូ យន់, ហ៊ូ នឹម នៅកាន់កាប់ ។

ប្រុញៈ ហ៊ូ យន់, ហ៊ូ នឹម គាត់នៅហ្នឹងតែម្ដង?

ជ្រុនៈ គាត់នៅកាន់មេដឹកនាំ តែអត់ដែលចុះទៅជួបទេ ហ៊ូ យន់, ហ៊ូ នឹម, ខៀវ សំផន ។

ប្រុញៈ អ៊ំដែលឃើញខៀវ សំផន ដែរ?

ជ្រុនៈ ខ្ញុំអត់ដែលឃើញ មេធំៗអត់ដែល ។

ប្រុញៈ អ៊ំដែលជួបនួន ជា ទេ?

ជ្រុនៈ នួន ជា អត់ជួប ខ្ញុំជួបតែខាប់ ទូច ហ្នឹងមេបញ្ជាការ ខ្ញុំទៅកងតំបន់៣៣ ។

ប្រុញៈ អ្នកណាកាន់កាប់តំបន់?

ជ្រុនៈ កាលមុនខាប់ ទូច តែគាត់ស្លាប់ គេផ្ទេរគាត់នៅក្រោយគេផ្ទេរចំទាហាបលន់ នល់ ។

ប្រុញៈ អ៊ំនិយាយមិញហ្នឹងថាគេបំបាត់លោក បំបាត់ស្ដេចក្នុងអំឡុងឆ្នាំណាអ៊ំ?

ជ្រុនៈ ឆ្នាំ៧៣ ចុង៧៣ ។

ប្រុញៈ ប្រជុំហ្នឹងជាមួយពីណា?

ជ្រុនៈ ប្រជុំមេបញ្ជាការទ័ពយើង ។

ប្រុញៈ គាត់ហ្នឹងឈ្មោះអីគេ?

ជ្រុនៈ ទ័ពមេវរៈ កាលមេវរៈធំតែម្ដង ខាប់ ទូច ។

ប្រុញៈ តែប្រជុំជាមួយអ៊ំថាបំបាត់លោកសង្ឃ?

ជ្រុនៈ មេកងហា ។

ប្រុញៈ គាត់ឈ្មោះអីគេ?

ជ្រុនៈ ឈ្មោះ ធី ។

ប្រុញៈ គាត់និយាយម៉េចពេលហ្នឹង?

ជ្រុនៈ គាត់និយាយអនាគតទៅលោកគេបំបាត់ ស្ដេចក៏គេបំបាត់ ។

ប្រុញៈ និយាយឲ្យចំសាសនាគេបំបាត់តែម្ដងឬយ៉ាងម៉េចអ៊ំ?

ជ្រុនៈ គេបំបាត់ ។

ប្រុញៈ ចុះចាម កាន់សាសនាចាម?

ជ្រុនៈ អត់មាននិយាយ ។

ប្រុញៈ ចុះវៀតណាមចន្លោះហ្នឹងយ៉ាងម៉េចដែរ?

ជ្រុនៈ វៀតណាមពេលចន្លោះហ្នឹងអត់មានវៀតណាមមក ។

ប្រុញៈ ពេលហ្នឹងវៀតណាម ហើយនិងខ្មែរឈ្លោះគ្នាយ៉ាងម៉េចអ៊ី?

ជ្រុនៈ ដល់ពេលយើងវ៉ៃលន់ នល់ ចប់ទៅ ទៅវ៉ៃវៀតណាមទៀត ហ្នឹងខ្ញុំឈប់ធ្វើទ័ពហើយ ខ្ញុំទៅនៅភូមិព្រៃផ្កាំ កងចល័តតំបន់វិញ ហ្នឹងបែកចប់ភ្នំពេញអស់ ។

ប្រុញៈ សុំសួរមុន៧៥សិន មុនឆ្នាំ៧៥ខាងកងទ័ពខ្មែរក្រហម ហើយនិងកងទ័ពវៀតណាមដែលវ៉ៃគ្នាទេ?

ជ្រុនៈ អត់ វៀតណាមនៅប្រទេសវានោះ វ៉ៃជាមួយធាវគី ។

ប្រុញៈ ជាមួយវៀតកុង?

ជ្រុនៈ វៀតកុងជិទាន់៦៩-៧០ហើយទេ យួនហើយនិងយួនវ៉ៃគ្នា ។

ប្រុញៈ ចុះមកខាង៧២-៧៣ មានខាងកងទ័ព?

ជ្រុនៈ ហ្នឹងពួកលន់ នល់ វាយកពួកធាវគីមក យករថក្រោះ៧០-៧១ ។

ប្រុញៈ អ៊ីចឹង៧៣វ៉ៃខ្លាំង វ៉ៃលន់ នល់?

ជ្រុនៈ វ៉ៃលន់ នល់ ។

ប្រុញៈ វ៉ៃម្តុំណាវិញ?

ជ្រុនៈ វ៉ៃនៅខេត្តកំពង់ស្ពឺនៅម្តុំចល័ត កាប់កង់ ស្រែថ្កុង ដោះកញ្ជរ មុនដំបូងវ៉ៃក្រាំងតាសន វ៉ៃដេញទៅ លិច ចល័តហើយកាប់កង់ ហើយផ្សារស្រែថ្កុង បានដោះកញ្ជរ ។

ប្រុញៈ ដែលវ៉ៃចាប់បានលន់ នល់ ដែរអី?

ជ្រុនៈ វ៉ៃចាប់បានទាហាន ស្លាប់ដូចតែគ្នា ។

ប្រុញៈ ខាងលន់ នល់ ចាប់បានទាហានខ្មែរក្រហមដែរ?

ជ្រុនៈ ហ្នឹងហើយ ហើយខ្មែរក្រហមក៏ចាប់បាន យើងវ៉ៃបែកកាន់កាប់ ។

ប្រុញៈ យើងវ៉ៃបានខាងលន់ នល់ ចាប់បានធ្វើម៉េចទៅ?

ជ្រុនៈ ចាប់បានសម្លាប់ ។

ប្រុញៈ សម្លាប់នៅកន្លែងហ្នឹងតែម្តង?

ជ្រុនៈ បាទ! អត់មានគុក ។

ប្រុញៈ គេបញ្ជាឲ្យសម្លាប់ហ្នឹងតែម្តងឬយ៉ាងម៉េច?

ជ្រុនៈ ហ្នឹងហើយ ។

ប្រុញៈ ខាងណាអ្នកបញ្ជាមក?

ជ្រុនៈ ខាងទ័ពគស៊ូ ។

ប្រុញៈ ឈ្មោះអីគេដែលភាគច្រើនបញ្ជាឲ្យសម្លាប់?

ជ្រុនៈ កាលហ្នឹងហ៊ូ យន់, ហ៊ូ នឹម នៅនេះ តែបញ្ជាទ័ពមិនដឹងពីណាបញ្ជាផង មកក្រោមខ្ញុំមិនបានក្តាប់ ។

ប្រុញៈ ដល់ពេលប្រជុំ គេមានប្រាប់ថាចាប់បានទាហានលន់ នល់ ឲ្យសម្លាប់ចោលឬម៉េច?

ជ្រុនៈ ប្រជុំគេថាខ្មាំងចាប់បានឲ្យសម្លាប់ចោល សូម្បីតែគិញ លន់ នល់ ក៏សម្លាប់ លន់ នល់ ក៏សម្លាប់យើង ទៅវិញទៅមក ។

ប្រុញៈ ពេលហ្នឹងពាក្យថាខ្មាំងគេសំដៅពីណាខ្លះអ៊ំ? ជំនាន់៧៣?

ជ្រុនៈ សំដៅប្រជាជនយើងដូចគ្នាអីចឹង មួយនៅខាងលន់ នល់ ចេញមកប្រជាជនគេចាប់បានគេថាខ្មាំង ហើយយើងនៅខាងរំដោះ នៅខាងអ្នកតស៊ូហ្នឹងពេលណាគេចាប់បានគេថាយើងខ្មាំងវិញ ចាប់វះពោះដូចគ្នា ។

ប្រុញៈ សម្លាប់ដូចគ្នា?

ជ្រុនៈ បាទ! យើងក៏ចាប់គេវះពោះ ។

ប្រុញៈ ចុះវៀតណាមពេលហ្នឹងគេចាត់ទុកថាខ្មាំងអត់?

ជ្រុនៈ វៀតណាមអត់បានចូលមក ។

ប្រុញៈ ចុះមានគេចាត់ទុកថាវៀតណាមខ្មាំងទេពេលហ្នឹង?

ជ្រុនៈ វៀតណាមចាត់ទុកខ្មាំង ។

ប្រុញៈ អីចឹងពេលហ្នឹងមានចាប់បានគិញវៀតណាមទេ?

ជ្រុនៈ អត់មានវៀតណាម ។

ប្រុញៈ ពេលហ្នឹងហេតុអីបានគេចាត់ទុកថាវៀតណាមជាខ្មាំង ព្រោះលន់ នល់ យើងដឹងហើយវ៉ៃតទល់គ្នា ។

ជ្រុនៈ ជាមួយលន់ នល់ តែវៀតណាមអត់មានវ៉ៃណា ព្រោះពួករំដោះគេស្អប់វៀតណាម ។

ប្រុញៈ ម៉េចអីចឹងអ៊ំ?

ជ្រុនៈ មេដឹកនាំគេស្អប់វៀតណាម ដល់បែក៧៥ ទើបកេណ្ឌទ័ពទៅវ៉ៃវៀតណាមតាមព្រំដែន ។

ប្រុញៈ មេដឹកនាំអ៊ំសំដៅពីណាគេ?

ជ្រុនៈ មេដឹកនាំទាល់តែបែក៧៥ ហើយ លឺសូរឈ្មោះតាម៉ុក កាលហ្នឹងគាត់នៅកាន់ភូមិភាគនិរតី ៧៦-៧៧ ហើយ ។

ប្រុញៈ	អ៊ីចឹងតាម៉ុក គាត់ស្អប់វៀតណាមខ្លាំង?

ជ្រនៈ	បាទ!

ប្រុញៈ	ចុះប៉ុល ពត?

ជ្រនៈ	អានេះបញ្ញាមកពី ប៉ុល ពត ព្រោះតាម៉ុក គាត់មេភូមិភាគនីរតី ។

ប្រុញៈ	អ៊ុំបានលឺតាម៉ុក និយាយផ្ទាល់ថាស្អប់វៀតណាមទេ?

ជ្រនៈ	អាហ្នឹងខ្ញុំ៧៦-៧៧ខ្ញុំនៅកងចល័តភាគហ្នឹង ទៅនៅគាត់ជាមួយគាត់ គាត់ដើរមកក្បែរពេង ខ្ញុំធ្វើការ មកជួបអាដែងតារិន កងពលទី២ គណៈតំបន់៣៣ ។

ប្រុញៈ	តារិន ហ្នឹងគាត់ប្រធានកងពលផង និងគណៈតំបន់៣៣ផង?

ជ្រនៈ	កាលមុនគាត់ធ្វើគណៈតំបន់៣៣ មួយតំបន់៣៣ហ្នឹងវាមាន៣ខេត្ត កំពត, តាកែវ, កំពង់ស្ពឺ ។

ប្រុញៈ	ចុះកំពត ពីណាគេកាន់?

ជ្រនៈ	តាពក ក៏តាម៉ុក រួម៣ខេត្តហ្នឹង ។

ប្រុញៈ	ចុះអ៊ុំមានដែលចូលប្រជុំជាមួយតាម៉ុក ទេ?

ជ្រនៈ	ខ្ញុំអត់ដែលបានផង ។

ប្រុញៈ	ចុះថ្នាក់បន្ទាប់អ៊ុំ មេអ៊ុំពីណាគេ?

ជ្រនៈ	មេខ្ញុំអឿន ។

ប្រុញៈ	គាត់ប្រធានកងពល?

ជ្រនៈ	គាត់ប្រធានកងវរៈ ។

ប្រុញៈ	ហ្នឹងឆ្នាំ៧៣តាម៉ុក ស្អប់យួន-វៀតណាមតាំងពីហ្នឹងអ៊ុំ?

ជ្រនៈ	ស្អប់វៀតណាមហ្នឹង វៀតណាមអត់ដែលចូលមកផង គេប្រជុំតែជាមួយលន់ នល់ ។

ប្រុញៈ	តែឆ្នាំ៧៣ហ្នឹងមានកំណត់ខ្លាំង ថាលន់ នល់, វៀតណាមសុទ្ធតែខ្លាំង?

ជ្រនៈ	បាទ!

ប្រុញៈ	មកដល់ឆ្នាំ៧៤?

ជ្រនៈ	៧៤អាហ្នឹងចុង៧៤ខ្ញុំឈប់ធ្វើ ខ្ញុំគ្រុនឈឺ មកផ្ទះប្រធានគេដក គេខ្ចីស្បែកជើងកង់ឡាន យើងហ្នឹង ហើយយើងគ្រុនឈឺនៅផ្ទះគេខ្ចី ប្រធានស្រី១វាអត់មានស្បែកជើងកង់ឡាន វាអត់ទៅមុខ វានៅក្រោយ វាចាំដកពីយើង ។

ប្រុញៈ	អ៊ុំឈឺគេដកស្បែកជើងវិញ?

ជ្រនៈ	គេមកយើងដែរ គេមកខ្ចីស្បែកជើង៣ក់ ខ្ចីទៅរហូត ។

ប្រុញៈ ពេលហ្នឹងអ៊ំកាន់តួនាទីអីគេ?

ជ្រួនៈ ខ្ញុំអត់ដែលកាន់តួនាទីអី ខ្ញុំអត់បានប្រធានក្រុមផង ។

ប្រុញៈ សុំសួរតិច បើគេចាប់វៀតណាមបានគេធ្វើម៉េច?

ជ្រួនៈ ចាប់វៀតណាមបាន អាចុងក្រោយនេះ ដល់បែកលន់ នល់ ហើយ វ៉ៃជាមួយវៀតណាមនេះ គេសម្លាប់ ។

ប្រុញៈ ចាប់បានដឹងតែសម្លាប់?

ជ្រួនៈ បាទ!

ប្រុញៈ ចុះប្រជាជនសាមញ្ញធម្មតាចាប់បាន?

ជ្រួនៈ ប្រជាជន?

ប្រុញៈ ចាប់បានជនជាតិវៀតណាម?

ជ្រួនៈ ប្រជាជនចូល ។

ប្រុញៈ គេប្រាប់ថាអត់ឲ្យជនជាតិវៀតណាមនៅតែម្តង?

ជ្រួនៈ ហ្នឹង គ្រាន់តែហ្នឹងជំនាន់លន់ នល់ ទម្លាក់សម្តេចភ្លាម លន់ នល់ ក៏សម្លាប់វៀតណាមដែរ ៧០ នៅតាកែវវៀតណាមរត់កាត់បឹង ប៉ូលីសជំនាន់ហ្នឹង ប៉ូលីសយើងមានតិចៗដែរ រត់កាត់បឹងខ្លះបាក់ដៃ រត់មិនទាន់ផង ខ្លះស្រីក្មេងហើយសម្លាប់ លន់ នល់ កាលមុនដំបូងស្អប់

ប្រុញៈ ខាងខ្មែរក្រហមពេលអីចឹងធ្វើដូចលន់ នល់ អត់?

ជ្រួនៈ ធ្វើដូចគ្នា ។

ប្រុញៈ សម្លាប់ដូចគ្នា?

ជ្រួនៈ បាទ!

ប្រុញៈ ហ្នឹងយើងចាប់បានត្រូវសួរឬម៉េចអ៊ំ បាននាំឲ្យសម្លាប់អីចឹង? ចាប់បានត្រូវសម្លាប់យកតែម្តង?

ជ្រួនៈ ចាប់បានចាំបាច់សួរអី ។

ប្រុញៈ អ៊ំធ្លាប់ឃើញគេសម្លាប់ទេ?

ជ្រួនៈ ដែល អាហ្នឹងកាលវ៉ៃជាមួយលន់ នល់ ឃើញចាប់បានទាហានខ្មែរ ខ្លះគេចង់បានប្រម៉ាត់គេវះពោះទាំងរស់ គេថាអត់ឲ្យបែកប្រម៉ាត់ ។

ប្រុញៈ យកប្រម៉ាត់ខាងណា?

ជ្រួនៈ ប្រម៉ាត់ខាងលន់ នល់ ។

ប្រុញៈ ចុះខាងវៀតណាម?

ជ្រន៖ វៀតណាមកាលហ្នឹងមិនទាន់ចូលណា៎ ទាល់តែយើងទៅវ៉ៃវាចូលដីវា កាលយើងចុង៧៧ ។

ប្រុញ៖ មុន៧៥ហ្នឹងសម្លាប់វៀតណាមអស់ច្រើនទេ?

ជ្រន៖ ហ្នឹងលន់ នល់ វាបោសសំអាតកាលទម្លាក់សម្តេចហើយភ្លាម វៀតណាមអត់មាននៅក្នុងដីខ្មែរណា ។

ប្រុញ៖ ឆ្នាំ៧៣-៧៤អត់មានវៀតណាមមកនៅក្នុងតំបន់អ៊ំទេ?

ជ្រន៖ មានតែកូនចៅវៀតណាម ។

ប្រុញ៖ ចុះកូនចៅវៀតណាមហ្នឹងឲ្យនៅអត់?

ជ្រន៖ កូនចៅវៀតណាមដូចថាម៉ែវៀតណាមលាក់ខ្លួនដល់ជំនាន់ប៉ុល ពត ក៏គេរកឃើញ ។ ចុងវៀតណាមមករំដោះហ្នឹងប៉ុល ពត ក៏សម្លាប់វៀតណាមដែរ សម្លាប់កូនចៅវៀតណាម ។

ប្រុញ៖ ឆ្នាំណា?

ជ្រន៖ ៧៧-៧៨ហើយ ។

ប្រុញ៖ ៧៨សម្លាប់វៀតណាម?

ជ្រន៖ ហ្នឹងហើយសម្លាប់ប្រជាជន ដូចថាយកប្រជាជនខ្មែរឲ្យដើរវ៉ៃផ្លូវរទេះ ។

ប្រុញ៖ ប្រពន្ធខ្មែរ ប្រពន្ធវៀតណាមម៉េចអត់យល់?

ជ្រន៖ ដូចថាវៀតណាមអីចឹងយកប្រពន្ធខ្មែរ បានកូន១-២អីចឹងក៏យកវៀតណាមហ្នឹងទៅសម្លាប់ដែរ ។

ប្រុញ៖ ចុះកូនហ្នឹង?

ជ្រន៖ ទុកប្រពន្ធនិងកូន ។

ប្រុញ៖ ហ្នឹងគេប្រាប់ណែនាំអីចឹងតែម្តង?

ជ្រន៖ បាទ!

ប្រុញ៖ ខាងណាគេអ្នកណែនាំ?

ជ្រន៖ ហ្នឹងប៉ុល ពត ។

ប្រុញ៖ ប៉ុល ពតផ្ទាល់?

ជ្រន៖ ទេ អាហ្នឹងបញ្ជាមកពីគណៈស្រុក គណៈតំបន់គេ តែបញ្ជាមកពីប៉ុល ពត ក៏មិនដឹង ព្រោះប៉ុល ពត គេនាយករដ្ឋមន្ត្រីហើយគេបញ្ជា ។

ប្រុញ៖ ហ្នឹងនៅក្នុងភូមិព្រៃផ្កាំហ្នឹងអ៊ំ?

ជ្រន៖ អត់ទេ នៅឃុំទ្រា ។

ប្រុញ៖ ស្រុក?

ជ្រន៖ ស្រុកសំរោង ។

ប្រុញ៖ ស្រុកសំរោង ខេត្តតាកែវ?

ជ្រន៖ ហ្នឹងហើយ ។

ប្រុញ៖ ហ្នឹងឆ្នាំណាអ៊ំ?

ជ្រន៖ ឆ្នាំ៧៩ ។

ប្រុញ៖ អ៊ីចឹង៧៨-៧៩មានគោលនយោបាយឲ្យសម្លាប់?

ជ្រន៖ ដើម៧៩ ។

ប្រុញ៖ ព្រោះអីបែក៧៩ខាងវៀតណាមចូល?

ជ្រន៖ កណ្តាល៧៩ ដល់វៃហើយវៀតណាមចូលមក មានអ្នកតស៊ូ វៀតណាមចូលមក ចុង៧៩ បែកប៉ុល ពតហ្នឹង ។

ប្រុញ៖ អ៊ីចឹងបែកប៉ុលពត មានគោលនយោបាយសម្លាប់អ៊ីចឹងដែរ?

ជ្រន៖ បែកប៉ុល ពត ហ្នឹងដល់ពេលរដ្ឋកម្ពុជាយើងមានអត់មានសម្លាប់ ។

ប្រុញ៖ ខ្ញុំសុំសួរត្រឡប់?

ជ្រន៖ អាហ្នឹងជិតបែកប៉ុល ពត វាដើរ ដូចថាវៀតណាមចូលមក ដល់វៀតណាមត្រូវចូលឆ្នាំ សែនមាឃ ប៉ុល ពត ចុះមកវិញដើរវៃចោល ។

ប្រុញ៖ ដើរវៃកូនវៀតណាម?

ជ្រន៖ ហ្នឹងហើយ ។

ប្រុញ៖ ហ្នឹងឆ្នាំណា?

ជ្រន៖ ពាក់កណ្តាល ជាង៧៩ ។

ប្រុញ៖ មានន័យថាខ្មែរក្រហមចាញ់ហើយ រត់ចូលព្រៃ?

ជ្រន៖ រត់ចូលព្រៃ ដល់ហើយវៀតណាមដកថយ វៀតណាមមកជួយហ្នឹងដកថយទៅ ប៉ុល ពត ចូលមួយសារ ដុតទីរួមខេត្តតាកែវ ។

ប្រុញ៖ អ៊ីចឹងប៉ុល ពត ចូលមកគឺវៀតណាមទាំងប៉ុន្មានសម្លាប់ចោលទាំងអស់?

ជ្រន៖ ហ្នឹងហើយ ប្រជាជនវៀតណាម ។

ប្រុញ៖ នៅហ្នឹងសម្លាប់ចោលទាំងអស់?

ជ្រន៖ សម្លាប់ចោល ធ្លាប់រស់នៅហ្នឹងយូរណាស់ហើយ គ្រាន់តែម៉ែឪមកតាំងពីជំនាន់សម្តេច សីហនុ គាត់ស្លាប់អស់ ឲ្យតែជាប់ខ្សែវៀតណាមវាវៃចោលអស់ ។

ប្រុញ៖ ហ្នឹងក្នុងខេត្តណា?

ជ្រន: ខេត្តតាកែវ ។

ប្រុញ: ពេលហ្នឹងខាងទាហានខ្មែរក្រហមចូលកាន់កាប់ប៉ុនៅទេ?

ជ្រន: ខ្មែរក្រហមដល់ហើយវៀតណាមទៅសែនចូលឆ្នាំយួនហ្នឹងមកវិញ ប៉ុល ពត រត់ទៅភ្នំវិញ រត់មករហូត ។

ប្រុញ: វាចូលភ្លាមចេញមកវិញភ្លាម?

ជ្រន: ហ្នឹងហើយ វាដើរទៅគ្រប់គ្រងដូចថាឥឡូវវៀតណាមចូលដល់មកហ្នឹងគ្រប់គ្រងហើយទៅសែនមាយ ដកចេញពីខេត្តតាកែវ ទៅចូលឆ្នាំយួន ប៉ុល ពត វាឆ្លៀតចូលបាន៦-៧ថ្ងៃមួយអាទិត្យ ដើរវៃ ។

ប្រុញ: សម្លាប់អស់ច្រើនទេកាលហ្នឹង?

ជ្រន: សម្លាប់អស់ច្រើន ប្រជាជនខ្មែរដែលរៀបការ ដូចថាវៀតណាមទៅប្រហែលជា៨-១០ថ្ងៃហ្នឹង វាមកអីចឹង អ្នកណាដែលម៉ែឪរៀបឲ្យសែននេះហ្នឹង ក៏វាវៃចោល វៃទាំងប្រុស ទាំងស្រី វៃទាំងគូ វៃទាំងម៉ែឪទៀត ម៉ែឪអ្នករៀប ។

ប្រុញ: សំខាន់ឲ្យតែជាប់វៀតណាម?

ជ្រន: អត់ជាប់វៀតណាម ខ្មែរយើងហ្នឹងក៏ដោយ វាអត់ឲ្យរៀបឲ្យ ។

ប្រុញ: ហ្នឹងចុងឆ្នាំ៧៩ហើយ?

ជ្រន: ហ្នឹងហើយ ។

ប្រុញ: ដល់ពេលហើយប៉ុល ពត រត់មកភ្នំរហូតមក?

ជ្រន: រត់មកភ្នំវិញរហូតមក ។

ប្រុញ: ក្រៅពីខេត្តតាកែវប៉ុល ពត ដែលទៅវៃខេត្តណាទៀតទេ សម្លាប់វៀតណាម?

ជ្រន: វៀតណាមសម្លាប់គ្រប់តែខេត្ត ។

ប្រុញ: ឲ្យតែជនជាតិវៀតណាម?

ជ្រន: ឲ្យតែជាប់ខ្សែវៀតណាម ។

ប្រុញ: ចុះកូនតូចៗអីឲ្យតែថាជាប់សម្លាប់ចោលទាំងអស់?

ជ្រន: ហ្នឹង ចិនក៏វៃចោល ឆ្នល់វៃចិនចោលដែរហើយប៉ុល ពត ទៅរៀនស្រុកចិន ។

ប្រុញ: ចុះក្នុងអំឡុងឆ្នាំពេលប៉ុល ពត នៅកាន់អំណាច ហ្នឹងជនជាតិវៀតណាមដែលទុកឲ្យអត់ទុកឲ្យនៅកម្ពុជា?

ជ្រន: អត់ទុក ។

ប្រុញ: ដេញទៅស្រុកអស់តែម្តង?

ជ្រួនៈ  វៃចោល ចិនក៏វៃ ។

ប្រុញៈ ធ្លាប់ចាប់បានច្រើនទេអ៊ំ? ពេលសម័យប៉ុល ពត កាន់អំណាច?

ជ្រួនៈ កាន់អំណាចចិនគេអត់មានចាប់ទេ គេជួរជាឥឡូវឲ្យទៅដាំដំឡូងដកពីភូមិ ដកចិនៗឲ្យដាំដំឡូងនៅស្វាយដង្កោល បៀតសៃរ៉ា បៀតព្រៃដំបង ជាប់ស្រុកព្រៃកប្បាសហ្នឹង ស្វាយដង្កោលវាម៉ុំហ្នឹង ហើយកន្លែងចេញពីស្វាយបឿនទៅបៀតដើងគួនវាមានទឹក ទឹកទន្លេឡើងមក ដល់ហើយទៅវាមានអូរគេចម្លងទូកយកទៅវៃចោល ក្មេងចាប់បោកនឹងដើមឈើ ចាប់ជើងបោក ។

ប្រុញៈ ហ្នឹងហើយជំនាន់ប៉ុល ពត វៀតណាមចាប់បានច្រើនទេ?

ជ្រួនៈ ចាប់បាន ។

ប្រុញៈ ចាប់បានធ្វើម៉េចទៅ?

ជ្រួនៈ ចាប់បានសម្លាប់ ។

ប្រុញៈ សម្លាប់ចោលទាំងអស់តែម្ដង?

ជ្រួនៈ បាទ!

ប្រុញៈ អត់ដែលមានដោះលែងទៅ?

ជ្រួនៈ អត់មានដោះលែង បើខ្មែរយើងលួចចិញ្ចឹមមាន់ យកមាន់ស្ងោរស៊ី លួចមាន់ ដូចជាចិញ្ចឹមមាន់នៅក្នុងផ្ទះអ៊ីចឹង យើងថ្ងៃល្ងាចមកអត់បាយ មកវិញល្ងាចយើងលួចស្ងោរមាន់ស៊ី ដាក់កំសៀវមានឈ្លបវា មកតាមដានយប់ ហើយយើងអង្គុយលេងតាមគ្រែអ៊ីចឹងវាលូនចូលឲ្យតែអង្គុយ២-៣នាក់វាលូនចូលតាមស្ដាប់ ហើយវាដាក់គុកយើង គុកអត់ចាំបាច់មានជញ្ជាំងទេ គុកផ្ទះអ៊ីចឹង បើកជញ្ជាំងចេញក៏មិនដឹងរត់ទៅណា ។

ប្រុញៈ អ៊ំសុំសួរបញ្ជាក់រឿងប៉ុល ពត ទៅសម្លាប់វៀតណាមនៅខេត្តតាកែវហ្នឹង ប៉ុល ពតនាំកងទ័ពណាទៅ?

ជ្រួនៈ តែប្រជាជនដែលគេអ្នកនៅហ្នឹង ទៅពីកំពង់ស្ពឺទៅមេគេ កាន់គណៈឃុំ ដូចជាឃុំទ្រាអ៊ីចឹងស្រុកសំរោងគេយកពីខេត្តកំពង់ស្ពឺមក យកមកកាន់គណៈឃុំ គណៈស្រុក ។

ប្រុញៈ អ៊ីចឹងឆ្នាំ៧៩ដែលវៀតណាមវៃចូលកម្ពុជាខាងប៉ុល ពត មានកងទ័ពនៅកំពង់ស្ពឺខ្លះដែរ?

ជ្រួនៈ មាន ។

ប្រុញៈ អ៊ីចឹងមានន័យថាកន្លែងហ្នឹងប៉ុល ពត នៅកាន់កាប់?

ជ្រួនៈ នៅកាន់កាប់ដល់ពេលយើងវៃខ្លាំងបានរត់ឡើងទៅភ្នំ រដ្ឋកម្ពុជាវៃខ្លាំង ។

ប្រុញៈ ពេលហ្នឹងប៉ុល ពត ដឹកនាំកងទ័ពពីណាមកខ្លះ?

ជ្រុន: កងទ័ពវៃដាមួយលន់ នល់ ពីមុនមក ។

ប្រុញ: កងទ័ពអីគេអ៊ី? លេខប៉ុន្មាន?

ជ្រុន: កាលមុនកងទ័ពពេញប្រទេស បើខ្ញុំនៅតំបន់៣៣ តំបន់៣៣រត់ឡើងលើភ្នំតាមប៉ុល ពត ប្រជាជនក៏រត់ដែរ ប្រជាជនដែលរស់នៅជាមួយប៉ុល ពត ដូចថ្ងៃធ្វើកងទ័ពនៅជាមួយប៉ុល ពត វាកៀរទៅឡើងភ្នំដែរ ។

ប្រុញ: អ៊ីចឹងកងទ័ពនៅតំបន់៣៣រត់ទៅជាមួយប៉ុល ពត ទាំងអស់?

ជ្រុន: រត់ទៅខ្លះ ខ្លះអត់ ។

ប្រុញ: ហើយមកសម្លាប់វៀតណាមនៅអំឡុងពាក់កណ្ដាល៧៩ កងទ័ពរត់ពីហ្នឹងទៅដែរ?

ជ្រុន: អ្នកឈ្លបនៅហ្នឹង ឈ្លបប្រជាជននៅក្នុងភូមិ គេធ្វើឈ្លបប៉ុល ពត គេស្គាល់ដឹងនេះ វៀតណាម ដឹងនេះខ្មែរ ប្រាប់គណៈឃុំវានៅកំពង់ស្ពឺវាដឹងអី ទាល់តែអ្នកនៅស្រុកប្រាប់ ដឹងនេះអ្នកមាន នេះអ្នកក្រ ទៅពីយើងបាទីធ្វើគណៈឃុំ ដឹងនេះអ្នកមាន នេះអ្នកក្រ ហើយអ្នកមានគេឲ្យទៅកន្ធៃជ្រើរ អ្នកក្រគេពេញសិទ្ធិជំនាន់ប៉ុល ពត គេយកតែអ្នកអត់ចេះ អក្សរយកទៅធ្វើការ ។

ប្រុញ: អ៊ីដឹងថាពីណាគេមេដឹកនាំតែម្ដង មកសម្លាប់នៅខេត្តតាកែវ? ដឹកនាំទ័ពមក?

ជ្រុន: ហ្នឹងខ្ញុំដឹងតែឃុំ ។

ប្រុញ: ឈ្មោះអីគេ?

ជ្រុន: ដឹងស្លាប់នៅ ស្លាប់បាត់អស់ហើយមើលទៅ ។

ប្រុញ: ឈ្មោះអីគេ?

ជ្រុន: ឈ្មោះខន នោះមួយ ។

ប្រុញ: ខន ហ្នឹងថានេះគាត់អីគេ?

ជ្រុន: គណៈគេ គណៈឃុំ មេឃុំ ហ្នឹងមកពីកំពង់ស្ពឺ ។

ប្រុញ: ហើយខន ហ្នឹងគាត់មានទំនាក់ទំនងជាមួយពីណាគេលើ?

ជ្រុន: ទំនាក់ទំនងមេគេមកពីលើ គណៈស្រុក តាឆែល ។

ប្រុញ: តាឆែល គណៈស្រុកអីគេ?

ជ្រុន: គណៈស្រុកសំរោង ហ្នឹងកាលស្រុកសំរោង តែកាលហ្នឹងគេមិនហៅស្រុកសំរោងទេ គេថា ស្រុក៥៤ ។

ប្រុញ: អ៊ីចឹងតាឆែល ហ្នឹងគាត់ដឹកនាំ ឬមានលើតាឆែល ហ្នឹងទៀត?

ជ្រុន: មានគេអ្នកដឹកនាំលើហ្នឹងទៀត ។

ប្រុញៈ ឈ្មោះអីគេ?

ជ្រនៈ ខ្ញុំអត់ស្គាល់ដែរ មេលើៗ ។

ប្រុញៈ ចុះតាឆែល ហ្នឹងគាត់ទំនាក់ទំនងយ៉ាងម៉េចជាមួយតាម៉ុក?

ជ្រនៈ តាឆែល ហ្នឹងគាត់ខាងគណៈស្រុកគេ បើតាម៉ុក គាត់ខាងទ័ព ទ័ពភូមិភាគ មេភូមិភាគ ។

ប្រុញៈ អ៊ំអាចគិតថាសម្លាប់នៅតាកែវ តាម៉ុក គាត់បានចូលមកសម្លាប់ពេលហ្នឹងអត់?

ជ្រនៈ តាម៉ុក អត់បានចូលទេ ។

ប្រុញៈ ហេតុអីអត់មានតាម៉ុក មក?

ជ្រនៈ គាត់ម៉េចមក គាត់កាន់ទ័ព អានោះនៅលើអាដែងទ័ពដោយឡែក អាដែងអ្នកធ្វើការគណៈស្រុក គណៈតំបន់គេដោយឡែក ។

ប្រុញៈ ចង់និយាយថាពេលមកសម្លាប់ទ័ពនៅតាកែវ?

ជ្រនៈ អត់មានមក ។

ប្រុញៈ កំលាំងមកពីស្រុកសម្លាប់?

ជ្រនៈ ហ្នឹងហើយ ប្រជាជននៅក្នុងភូមិជាមួយគ្នាហ្នឹងគេធ្វើឈ្លប ។

ទត្ថៈ អ៊ំមានដឹងមូលហេតុអីបានគេសម្លាប់ជនជាតិវៀតណាមអីចឹងទេ?

ជ្រនៈ គេស្អប់វៀតណាម ចិនក៏សម្លាប់ ។

ទត្ថៈ គេស្អប់ម៉េច?

ជ្រនៈ ដូចនៅពន្លៃ ស្រុកព្រៃកប្បាសហ្នឹងចិនខ្លះមកដល់ គេបញ្ជូនមកស្វាយ ។

ប្រុញៈ អ៊ំទៅដល់ភូមិពន្លៃហ្នឹងដែរ?

ជ្រនៈ ពន្លៃ កំពែង ខ្ញុំទៅដល់ ព្រៃល្វា ។

ប្រុញៈ ពីណាគេគ្រប់គ្រងនៅពន្លៃ?

ជ្រនៈ មិនដឹងពីណាគ្រប់គ្រងព្រោះគេដោយឡែក ។

ប្រុញៈ តែតាម៉ុក ទៅដល់ពន្លៃហ្នឹងដែរ?

ជ្រនៈ តាម៉ុក គេនៅកាន់ទ័ព គេកាន់ទ័ពនៅភ្នំបូរី កំពង់អំពិល សុទ្ធតែទ័ពគេនៅលើភ្នំ ឲ្យកាន់កងចល័តផង ។

ប្រុញៈ សុំសួរត ពេលពាក់កណ្ដាល៧៩ កំលាំងខ្មែរក្រហមមកវាយឆ្នក់ខេត្តតាកែវសម្លាប់វៀតណាមហើយរត់មកភ្នំវិញ អ៊ំនិយាយមុនហ្នឹងត្រូវអីចឹងទេ?

ជ្រនៈ ហ្នឹង ។

ប្រុញៈ ដល់ពេលរត់មកភ្នំហើយ ប៉ុល ពត រត់មកភ្នំហ្នឹងជួបពីណាខ្លះ? តាម៉ុកអីទេ?

ជ្រនៈ គេមកជួបមេគេទៅ ខ្ញុំអត់មានរត់មកណា ។

ប្រុញៈ អត់បានរត់ទៅជាមួយប៉ុល ពត ហ្នឹងទេ?

ជ្រនៈ ខ្ញុំអត់ទៅព្រៃភ្នំ ។

ប្រុញៈ អ៊ីចឹងអ៊ំដាច់ខ្សែរយៈលែងស្គាល់គាម៉ុក តាំងពីត្រឹមហ្នឹងឬក៏ម៉េច?

ជ្រនៈ ហ្នឹងហើយ លែងស្គាល់តាម៉ុក កាលពីរត់ស្គាល់ ។

ប្រុញៈ ចុះប៉ុលពត ឈប់ទាក់ទងស្គាល់គាត់?

ជ្រនៈ ឈប់ទាក់ទងហើយ ដល់ពេលវៀតណាមចូលមកមួយហ៊ឹកៗហ្នឹង វាកៀរយើងទៅទៀតតែ យើងអត់ទៅតាមវា ។

ប្រុញៈ វៀតណាមកៀរទៅដែរ?

ជ្រនៈ អត់ទេ ពួកប៉ុល ពត ហ្នឹង គណៈឃុំគេហ្នឹង ប្រធានឃុំគេឲ្យយើងទៅយើងអត់ទៅគេចមក ផ្ទះវិញ មកទាំងអស់មក ដូចថាវៀតណាមចូលមកអ៊ីចឹងព្រលឹមឡើងគេនាំយើងរត់ដល់ ពេលយប់យើងរត់មកវិញមក បរទេះគោមកវិញ មកគាស់ដំឡូង គាស់សាគូក្រហមគេដាំ ហ្នឹង ព្រលឹមឡើងប្រធានចុងភៅគេ កណ្តាលយប់គេមកជញ្ជូនពីផ្ទះយើងទៅទៀតគេថា យើងអ្នកបំបះបំបោរ ដល់ហើយទៅប៉ុល ពត លែងមក ។

ប្រុញៈ ពេលវៀតណាមចូលមកភ្លាមអ៊ំនៅណា?

ជ្រនៈ ខ្ញុំរត់ពីព្រៃផ្តៅមក ពីកងចល័ត ។

ប្រុញៈ ពេលវៀតណាមវ៉ៃចូលភ្នំពេញអ៊ំនៅព្រៃផ្តៅទេ ឬម៉េច?

ជ្រនៈ ហ្នឹងហើយ ។

ប្រុញៈ ហើយអ៊ំរត់ពីហ្នឹងទៅណាវិញ?

ជ្រនៈ រត់ពីហ្នឹងមកផ្ទះ រត់មកផ្ទះម៉ែឪ គេនាំចេញពីហ្នឹងទៅបៀតភ្នំជីសូរទេ ប្រជាជនរត់មកមុនខ្ញុំ ទៀតប៉ុល ពត គេកៀរទៅ ។

ប្រុញៈ ប៉ុន្តែអ៊ំនៅព្រៃផ្តៅម៉េចបានជួបប៉ុល ពត?

ជ្រនៈ ហ្នឹងកងចល័តប៉ុលពត ។

ប្រុញៈ អ៊ំកងចល័តរបស់ប៉ុលពតតែម្តង?

ជ្រនៈ ហ្នឹងហើយ ។

ប្រុញៈ អ៊ីចឹងបានន័យថាប៉ុលពតបញ្ជូនទ័ពឬម៉េច?

ជ្រន: ហ្នឹងគណៈ ៗ កងគេបញ្ជាផ្ទាល់គេឲ្យយើងរត់ទៅ ឲ្យមកតាមឆ្មោកយោលមកពន្លៃ ហើយខ្ញុំអត់មកតាមពន្លៃ ខ្ញុំមកតាមទំនប់លិចតាមកោះទ្រាលមកលិចមករកផ្ទះ អ្នកទៅតាមវាទៅ វាកៀរទៅនាំទៅព្រៃភ្នំ ។

ប្រុញ: អ៊ំជួបប៉ុល ពត ដំបូងបំផុតពេលណា?

ជ្រន: ប៉ុល ពត ជួបតាំងពីឆ្នាំ៧៣ជួបតែម្តង ។

ប្រុញ: គាត់និយាយយ៉ាំងម៉េចដែរកាលហ្នឹង?

ជ្រន: ជួបខ្ញុំនៅឆ្ងាយគេនិយាយ គេមកប្រជុំ ។

ប្រុញ: គេមកប្រជុំគេនិយាយយ៉ាំងម៉េច?

ជ្រន: យើងអត់មានបានទៅបៀតគេ ។

ប្រុញ: ក្រៅពីប៉ុលពត អ៊ំបានចូលប្រជុំជាមួយពីណាទៀត?

ជ្រន: ប្រជុំតែកងហា នាយអាយ ។

ប្រុញ: អ៊ីចឹងជួបតែប៉ុល ពត ម្តងក្រៅពីហ្នឹងជួបប្រជុំជាមួយកងវរៈ?

ជ្រន: កងហា កងរយយើង ។

ប្រុញ: ហ្នឹងក្នុង៧៣?

ជ្រន: ហ្នឹងហើយ ដល់ចុង៧៣ចូល៧៤ខ្ញុំឈឺគ្រុនក្តៅ មកផ្ទះ ។

ប្រុញ: អ៊ំពាក់ព័ន្ធរឿងជនជាតិចាម ដូចវៀតណាមអត់ទេ?

ជ្រន: ចាមអត់មានលឺនិយាយ ។

ប្រុញ: កាន់សាសនាចាមអីគេអត់ថាអី ឬម៉េចដែរ?

ជ្រន: អត់មានអ្នកណាកាន់សាសនាអីណាទៅស្រុកខ្ញុំ ។

ទត្តៈ អ៊ំដែលឃើញគេសម្លាប់ប្រជាជនវៀតណាមផ្ទាល់ភ្នែកទេ?

ជ្រន: ឃើញ វាវ៉ៃនឹងដូវរទេះ ។

ទត្តៈ វ៉ៃមុខយើងតែម្តង?

ជ្រន: ដូវរទេះយើងអ៊ីចឹង ឈ្លបវាដើរដូចវៀតណាមដកទៅចូលឆ្នាំ ឈ្លបវាចូលមកមួយឈុល ប្រហែលជា១០ថ្ងៃ ដូវរទេះយើងវាដាក់ក្នុងចំបើង វាស៊ីកក្នុងហ្នឹង២-៣វាលីដើរឈ្លបវា ៣-៤នាក់ វាហៅយើងចេញពីផ្ទះមក ដូចថាផ្ទះយើងនៅអ៊ីចឹងហៅយើងចេញទៅផ្ទល់ មានកាំភ្លើងវា អ្នកបណ្តើរយើងទៅដោយខ្សែក កាំភ្លើងវាចាំភ្ជង់យើងដោយខ្សែក អាវា នៅតាមដូចភូមិយើងដូរតាមផ្ទល់វានៅក្រៅៗភូមិសងខាង គ្នាវាត្រៀមខ្វាចយើងរត់ ហៅទៅអ៊ីចឹងទៅដល់វាវ៉ៃកាំភ្លើងយើងឲ្យលុតជន្លង់ ដូវរទេះដកចេញពីចំបើង ។

ទត្តៈ	វៃវៀតណាម?

ជ្រួនៈ	វៃប្រជាជនយើងផង វៀតណាមក៏វៃ ។

ទត្តៈ	អ៊ំឃើញផ្ទាល់ភ្នែកតែម្តង?

ជ្រួនៈ	យើងលួចមើលពីផ្ទះទៅមិនហ៊ានចេញទេ តែដើរមានតែពួកឈួបប៉ុល ពត ដើរតាមថ្នល់ ប្រជាជនតែឃើញនេះចូលផ្ទះអស់លួចចាំមើលតែវាទេ មិនដឹងវាទៅហៅប្រជាជនណា អ្នកណាខុស អ្នកណាត្រូវ ។

ប្រុញៈ	នៅក្នុងឆ្នាំណាអ៊ំ?

ជ្រួនៈ	ហ្នឹងចុង៧៩ មុនវារត់ទៅភ្នំវិញ ។

ទត្តៈ	អ៊ំថាខ្មែរក្រហមស្អប់យួន ហ្នឹងយើងឃើញខ្មែរក្រហមសម្លាប់ប្រជាជន ឬមួយទាហាន?

ជ្រួនៈ	សម្លាប់ប្រជាជន ។

ទត្តៈ	ឲ្យតែប្រជាជនវៀតណាមយកទៅទាំងអស់?

ជ្រួនៈ	ឲ្យតែជាប់ខ្សែស្រឡាយវៀតណាម ។

ទត្តៈ	គេគ្រាន់តែនិយាយថាស្អប់ប៉ុណ្ណឹងទេ?

ជ្រួនៈ	យកប្រពន្ធខ្មែរគេអត់វៃប្រពន្ធទេ គេវៃតែវៀតណាម ។

ប្រុញៈ	ចុះអ៊ំបានលឺប៉ុល ពត ថាឲ្យសម្លាប់ប្តីប្រពន្ធវៀតណាមក្នុងឆ្នាំណា?

ជ្រួនៈ	ហ្នឹងខ្ញុំប្រជុំគេនិយាយចុង៧៣ ។

ប្រុញៈ	ប៉ុល ពត និយាយអីចឹង?

ជ្រួនៈ	ប៉ុល ពត គេអត់និយាយផ្ទាល់ទេ ក្រោមបញ្ជាគេ ។

ប្រុញៈ	អ៊ំមានឯកសារហ្នឹងសល់ទេ?

ជ្រួនៈ	អត់មានទេ ជំនាន់ហ្នឹងតែមាស ប្រាក់ ខ្ញុំទៅកងចល័ត ប្លាទីនគេចោលអារ៉ាត់អារ៉ាយកន្ទែង ហ្នឹងអត់មានយកផង អត់ដឹងថាយកធ្វើអី នៅជំនាន់របបគេអីចឹង ចាយមិនកើតផង ។

ប្រុញៈ	អីចឹងដឹងថាស្អប់វៀតណាមតាំងពី៧៣មក?

ជ្រួនៈ	ឃើញគេចោលខ្ញុំសុំយកមកធ្វើខ្សែដែកភ្លើងទៀតប្លាទីន ដល់បែកចុង៧៩យកទៅលក់ផ្សារ ដូរក្រណាត់ ប្លាទីនប៉ុណ្ណណឹគេចោលសុំគេចោលធ្វើខ្សែដែកកេះ ហើយដែកកេះជំនាន់ប៉ុល ពត មានតែខ្ញុំមួយទេ មានថ្នាំជក់ឬអត់ អាអស់ហ្នឹងសុំយកទៅដុតដង្ហួងកងចល័តដូចគ្នា គេ អត់មានដែកកេះ អត់មានថ្នាំជក់ មានមួយពេល១ ដូចខ្ញុំថាកងចល័តដកមកធ្វើការនៅ កំពង់ស្ពឺ បរក្របីមក ។

ប្រុញៈ	អ៊ំនិយាយថាប៉ុល ពត ហើយនិងតាម៉ុក ស្អប់វៀតណាមតាំងពី៧៣មកឬយ៉ាងម៉េច?

ជ្រន: ចុង៧៣ ។

ប្រុញ: ចុង៧៣មករហូត?

ជ្រន: ហ្នឹង ។

ប្រុញ: តែក្នុងពេលហ្នឹងអត់សូវសម្លាប់ច្រើនទេ?

ជ្រន: បាទ!

ប្រុញ: ដល់សម្លាប់ច្រើន?

ជ្រន: ដល់បែកភ្នំពេញ៧៦-៧៧ ។

ប្រុញ: ចាប់ផ្ដើមសម្លាប់ច្រើន?

ជ្រន: ហ្នឹង ។

ប្រុញ: ដល់ពេលក្រោយ៧៩នេះចាប់ផ្ដើមសម្លាប់?

ជ្រន: គេស្រាវជ្រាវប្រវត្តិរូប ។

ប្រុញ: ប្រវត្តិរូបម៉េច? គេស្រាវជ្រាវម៉េចទៅ?

ជ្រន: ប្រវត្តិរូបដូចយើងវៀតណាម ឬចិន គេស្រាវជ្រាវយើងអ្នកមាន ឬអ្នកក្រ ។

ប្រុញ: គេស្រាវជ្រាវម៉េចដឹងថាវៀតណាមទៅ?

ជ្រន: ម៉េចមិនដឹងបើអ្នកនៅស្រុកហ្នឹង អ្នកខ្លះកាលពីជំនាន់សម្ដេចសីហនុក្រ វានៅហ្នឹងវាដឹង ។

ប្រុញ: រាយការណ៍ថាវៀតណាម?

ជ្រន: រាយការណ៍ទៅមេឃុំ មេភូមិ វាដឹង ហើយមេភូមិ-មេឃុំមិននៅហ្នឹងណា វានៅខេត្តកំពង់ស្ពឺ គេឲ្យមកធ្វើគណៈឃុំ ដល់អ្នកនៅក្នុងភូមិហ្នឹងវាចាក់រុក អ្នកក្រ នេះអ្នកមាន នេះអ្នកកណ្ដាលជំនាន់សម្ដេចសីហនុ គេកៀបអ្នកមាន អត់ឲ្យបាយហូបគ្រប់គ្រាន់ ហើយដូចអ្នកមកពីភ្នំពេញ គេថាពួក៧៥ក៏គេយកទៅដាក់ភូមិមួយដុំ គេអត់ឲ្យបាយហូបគ្រប់គ្រាន់ គេឲ្យធ្វើការធ្ងរ ។

ប្រុញ: ពេលសម័យប៉ុលពត កាន់អំណាចគេចាត់ឲ្យទៅការពារនៅណា? អ៊ំនិយាយមុនហ្នឹង? ថាទៅភូមិព្រៃផ្ដៅទៅក្នុងឆ្នាំណា?

ជ្រន: ឆ្នាំ៧៦ ។

ប្រុញ: ហ្នឹងគេចាត់តាំងអ៊ំទៅធ្វើអីគេ?

ជ្រន: កងចល័ត ខ្ញុំខ្សែកូនចៅចិនដែរ កាលបែកភ្នំពេញខ្ញុំនៅក្នុងព្រៃ គេចាត់ឲ្យទៅដុតធ្យូងបៀតវត្តដុង បៀតបរសេដ្ឋ ដល់បែកភ្នំពេញខ្ញុំអត់បានមកដែរ ខ្ញុំនៅដុតធ្យូងគេកំណត់ឲ្យគ្រប់១ខែ ដល់បានមួយខែខ្ញុំមកផ្ទះវិញ បានសំរាកតែបន្តិចគេកេណ្ឌឲ្យមកកងចល័ត ។

ប្រុញៈ នៅព្រៃផ្ដាំហ្នឹងអ៊ី?

ជ្រនៈ កងចល័តនៅព្រៃផ្ដាំហ្នឹង មុនដំបូងទៅកងចល័តភាគ ។

ប្រុញៈ ភាគអីគេ?

ជ្រនៈ ភាគនីរតី ទៅកំពង់អំពិល កំពង់យោល ដល់ខ្ញុំនៅហ្នឹងវាអត់បាយហូបគ្រប់គ្រាន់ ដេកក្នុងបឹង មុខវត្តកំពង់យោល កំពង់អំពិលហ្នឹងជួបតាម៉ុក ហើយ ។

ប្រុញៈ ជួបតាម៉ុក នៅ?

ជ្រនៈ តាម៉ុក មកកន្លែងតារិន កងពល ។

ប្រុញៈ ក្នុងឆ្នាំណា?

ជ្រនៈ ហ្នឹង៧៦-៧៧ ខ្ទង់៧៦ គាត់ដើរមកពាក់តែអាវយឺតវាលក្លៀក អាវយឺតយើងសខ្សែប៉ុនៗនេះ ហើយតែខោខ្លីទេតាម៉ុក ។

ប្រុញៈ ហើយកាលហ្នឹងគាត់មានបាននិយាយម៉េចដែរ?

ជ្រនៈ គាត់អត់មាននិយាយអី ខ្ញុំឈឺដេកនៅពេទ្យហ្នឹង គាត់ថាដេកអីចឹងបានឈឺ ដេកថ្ងៃរសៀល គាត់មកតែកន្លែងកងពល ។

ប្រុញៈ អ៊ឹមកកងចល័តហ្នឹង ហើយមកការពារនៅព្រៃផ្ដាំ?

ជ្រនៈ អត់ទេ ហ្នឹងខ្ញុំនៅកំពង់អំពិល ដល់ពេលខ្ញុំនិយាយឲ្យអស់ ខ្ញុំរត់ពីចល័តភាគហ្នឹង មេកងរយខ្ញុំហ្នឹងកងភាគនៅខេត្តកំពត គេកាន់កងភាគតែគេត្រូវក្បាលនោះហើយគេថាកើតស្អីទេ ធ្វើការធ្ងន់ចេះតែប្រកាច់ ។

ប្រុញៈ គាត់ឈ្មោះអីគេ?

ជ្រនៈ ឈ្មោះអឿន ដល់ពេលវៀតណាមគេដកគាត់ទៅវៀតណាមទុំបាក់ដៃ គេលែងឲ្យកងទ័ពហ្នឹងកាន់ គេយកពួកស្រុក១០៦ តំបន់១៣នេះ ខាងត្បូងតាកែវយកមកកាន់ ខ្ញុំរស់នៅជាមួយពួកអស់ហ្នឹងអត់កើតវាខូចៗពេក រត់មកផ្ទះ គេតាមយកទៅវិញៗគេយកទៅចងមួយយប់បណ្ដើរពី គេចល័តភាគគេមានសិទ្ធិគេប្រមូលទៅកន្លែងស្រុក ម្ដុំបត់រការ បៀតថ្កល់ទទឹងដល់ហើយគេបណ្ដើរមកវិញយប់ គេចងខ្ញុំសុខចិត្តមកដល់កន្លែងគេ ស្រាប់គេថាយកបបរឲ្យគាត់ហូបផង មិនបបរណាចូលទៅម្ដងមួយៗ គេចងហើយគេដោតខ្សែអង្រឹងប្រឡោះដៃចងមួយយប់ហ្នឹងអត់បានដេក ព្រលឹមឡើងគេប្រជុំហើយបានគេស្រាយឲ្យយើងលែងរត់ខ្ញុំរត់ពីរដងចល័តភាគ ទៅម្ដងគេចងហ្នឹងហើយធ្វើការនេះរត់មកវិញទៀត ទៅភ្នំស្រឡូងគេដកទៅភ្នំស្រឡូងរត់មកវិញមាន់រងាវ ដើរមួយយប់ហ្នឹងគ្រាន់តែដេកមួយភាំងគេឲ្យយើងទៅ ទៅដើរឯងដល់មាន់រងាវហើយប្រជាជនហ្នឹងគេឡើងដាំបាយ បបួលគ្នាខ្ញុំនៅស្រុកភូមិ

ជាមួយគ្នាបាន២នាក់ ឥឡូវទៅមិនទៅ អ៊ីទៅ ទៅស្រុកយើងវិញ រត់មក មកបានដល់កន្លែងឃុំ ប្រធានឃុំគេឃ្លាំមើលយើងទៀត ដល់ហើយជួបវាធ្វើការជាមួយវាបានតែ២-៣ថ្ងៃ គេបញ្ជូនយើងមកចល័តតំបន់ មកព្រៃផ្ដៅទៀត មានបាននៅស្រុកណា ។

ប្រុញៈ អ៊ំនៅកំពតស្គាល់តាទិត ទេ?

ជ្រនៈ តាទិត?

ប្រុញៈ បាទ!

ជ្រនៈ កងចល័តមួយកំនរ តាទិត ដូចលឺឈ្មោះដែរ ។

ប្រុញៈ អីចឹងខាងក្រុមអ៊ំមិនមែននៅជាមួយគាត់ទេ?

ជ្រនៈ នៅជាមួយអឿន នៅជាមួយកងវរៈឈ្មោះអី កងទ័ពឈ្មោះឡេង កងវរៈ ។

ប្រុញៈ អីចឹងដល់ពេលសួរចុងក្រោយតិចចុះ ដល់ពេលចប់៧៩ទៅអ៊ំចេញពីណា ហើយមកនៅណាវិញ?

ជ្រនៈ ចប់៧៩មកនៅភូមិវិញ ។

ប្រុញៈ មកនៅស្រុកកំណើតវិញ?

ជ្រនៈ អត់ទេ អត់ទាន់នៅស្រុកកំណើត ៧៩នៅកន្លែងកំពង់ទ្រា តែនៅកន្លែងឃុំ ឃុំគេនៅអីចឹងយើងនៅតាមភូមិហ្នឹង នៅកំពង់ទ្រា ដល់ភូមិខ្ញុំភូមិសន្តិភាព ដល់ពេល៧៩-៨០-៨១ខ្ញុំមកនៅសំរោង អត់ទាន់បានទៅនេះ នៅធ្វើស្រែក្រុមសាមគ្គី ហ្នឹងជំនាន់រដ្ឋកម្ពុជាយើងគេឲ្យធ្វើស្រែក្រុមសាមគ្គី ដល់ហើយមកអីចឹងដល់៨២-៨៣បានខ្ញុំមកនៅភូមិវិញគេចែកដីឲ្យ

ប្រុញៈ អីចឹងលែងបានទាក់ទងស្គាល់ជាមួយប៉ុល ពត ជាមួយតាម៉ុក?

ជ្រនៈ បាទ! ហ្នឹងដល់រដ្ឋកម្ពុជាយើងដល់ហ៊ុនសែន វិញហើយ ចែកដីឲ្យម្នាក់២ម៉ែត្រកន្លះបណ្ដោយ១ហិចតា ចែកតាមមាត់ អ្នកណាមានកូន ជំនាន់រដ្ឋកម្ពុជាអ្នកណាមានកូនកាលហ្នឹងខ្ញុំមានកូនមួយ តែ៣នាក់ ប្រពន្ធមួយគេចែកតាមហ្នឹង អ្នកណាមានកូនច្រើនគេចែកតាមហ្នឹង ។

ប្រុញៈ ខ្ញុំមានរឿងច្រើនណាស់ត្រូវសួរអ៊ំ តែវាកាន់តែយប់ហើយ អ៊ំមានលេខទូរស័ព្ទទេ ហៅមកអ៊ំ ។

ជ្រនៈ ខ្ញុំអត់សូវចាំដែលទាល់តែមើល ០៩៧ ៨៨៨៨ ៣០៧ ។

ប្រុញៈ ឈ្មោះនាមត្រកូលអ៊ំពេញ?

ជ្រនៈ មៀច ជ្រន ។

ប្រុញៈ ចាំមើលម៉េចខ្ញុំអាចទាក់ទងសួរអ៊ំទៀត ហើយអ៊ំពិសារបាយនៅ?

ជ្រួនៈ នៅ ។

ប្រុញៈ អីចឹងអរគុណច្រើនអ៊ំបានផ្ដល់ព័ត៌មានចែករំលែកច្រើន ។

**ចប់**